ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ០៨

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

ក ស វ



# Work Activities

ប្រចាំខែសីហា ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម | ២ |
| ៣- | សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មប | ៤ |
| ៤- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង | ៥ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែកក្កដា ឆ្នាំ២០១២ | ៦ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# សញ្ញាសក្តិ និងឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់ សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ

កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គាំង គុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងអាជ្ញាធរសវនកម្មជាតិ។



អាជ្ញាធរសវនកម្មជាតិបានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញា សក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ ដោយអនុលោមតាមមាត្រា២៤ ជំពូកទី៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែកក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ។ ការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យនេះ យកតាមគំរូនៃព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្នុងក្របខណ្ឌផ្សេងៗ។

សេចក្តីព្រាងព្រះរាជក្រឹត្យនេះមានគោលបំណងបង្កើតសញ្ញាសក្តិ ឯកសណ្ឋាន និងកន្លាស់សញ្ញាសម្រាប់សម្គាល់មន្ត្រី ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ដើម្បីប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ។ សញ្ញាសក្តិសម្រាប់មន្ត្រីរាជការជាន់ខ្ពស់សវនកម្មរួមមាន សក្តិលើស្មា សក្តិចុងកអាវ និងសក្តិ ចុងដៃអាវ។ ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិមានឯកសណ្ឋានផ្លូវការ និងឯកសណ្ឋានប្រពៃណីជាតិ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិនិងឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ។

## សេចក្តីព្រាងច្បាប់ស្តីពី

# សហគមន៍កសិកម្ម

អង្គប្រជុំជំនាញបច្ចេកទេសចំនួន២០លើកគិតចាប់ពីថ្ងៃទី៥ ខែមិថុនា រហូតដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ដែលមាន ឯកឧត្តម **ឌុយ ឆៅ** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



សហករណ៍នៅព្រះរាជាណាចក្រកម្ពុជា បានចាប់បដិសន្ធិឡើងនៅក្នុងអំឡុងឆ្នាំ១៩៦០។ នៅពាក់កណ្តាលឆ្នាំ១៩៦៦ មានសហករណ៍សរុប ចំនួន៥១២ ដែលក្នុងនោះមានសហករណ៍ឥណទានចំនួន១៣ សហករណ៍ ពហុបំណងចម្រុះចំនួន ៣៩០ សហករណ៍ ឧបភោគបរិភោគចំនួន ៥៥ សហករណ៍ផលិតកម្មពិសេសចំនួន១៤ និងសាលាវិជ្ជាជីវសហករណ៍ចំនួន៤០។ នៅពេលនោះ សហករណ៍មានទុនបង្វិលសរុបប្រមាណជាង ១៣លានដុល្លារអាមេរិក។ ចលនាសហករណ៍មានសភាពខ្លាំងក្លា និងទទួលលទ្ធផលគួរឲ្យចាប់អារម្មណ៍ រហូតដល់រាជមន្ទីរ សហករណ៍បានបោះពុម្ពសៀវភៅអំពីសហករណ៍សម្រាប់ថ្នាក់បឋមសិក្សានៅកម្ពុជា។

នៅឆ្នាំ១៩៩៩-២០០១ ដោយមើលឃើញពីភាពចាំបាច់ក្នុងការជួយដល់កសិករ រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រពីអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ(FAO) បានរៀបចំព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងបុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម។ ចាប់ពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០១១ សហគមន៍អភិវឌ្ឍន៍កសិកម្មសរុបទាំងអស់មានចំនួនប្រមាណ២៧៣ បាននិងកំពុងដំណើរការប្រតិបត្តិការមុខរបរទាក់ទងទៅនឹងប្រព័ន្ធផលិតកម្មកសិកម្ម។ ជាការកត់សម្គាល់ ព្រះរាជក្រឹត្យស្តីពីការបង្កើតនិងការប្រព្រឹត្តទៅរបស់សហគមន៍អភិវឌ្ឍន៍កសិកម្មមានបទប្បញ្ញត្តិមិនទាន់គ្រប់គ្រាន់អំពីយន្តការគាំទ្រនិងនីតិវិធីដំណើរការ ស្របតាមស្ថានភាពរីកចម្រើនបច្ចុប្បន្ននេះ ដែលធ្វើឲ្យយើងនៅជួបបញ្ហាជាច្រើនក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម ទើបក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្មនេះឡើង។

សេចក្តីព្រាងច្បាប់នេះនឹងផ្តល់ប្រយោជន៍ជាច្រើនដល់ប្រជាកសិករ ដែលរួមមាន ៖

១. ផ្តល់សេវាកម្មគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុកាន់តែប្រសើរពីស្ថាប័នរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ដើម្បីលើកកម្ពស់ផលិតកម្មកសិកម្ម កសិធុរកិច្ច កសិឧស្សាហកម្ម ការបង្កើតកាលានុវត្តភាពការងារ និងការបង្កើតប្រាក់ចំណូលគ្រួសារ។

២. លើកកម្ពស់អំណាចទីផ្សាររបស់កសិករតាមរយៈការធ្វើទីផ្សាររួមគ្នា។

៣.ការពារផលប្រយោជន៍របស់ប្រជាកសិករតាមរយៈការចុះបញ្ជីនិងការទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤. លើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាកសិករស្របតាមគោលការណ៍គ្រឹះសហករណ៍អន្តរជាតិ។

៥. បង្កើតឲ្យមានយន្តការគាំទ្រសហគមន៍កសិកម្មចាប់ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន។

៦. ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ(១)។



អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះដោយយកចិត្តទុកដាក់ ហើយបានសម្រេចក សម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម។

# សេចក្តីព្រាងអនុក្រឹត្យស្តីពី ក្រមសីលធម៌ឆ្មប

កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អូន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **អ៊ុំ ម៉ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មប** ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងសុខាភិបាល។

ក្រសួងសុខាភិបាលបានខិតខំយកចិត្តទុកដាក់លើកកម្ពស់ការការពារនិងថែទាំសុខភាពជូនប្រជារាស្ត្រទាំងនៅជនបទដាច់ស្រយាល ទាំងនៅទីប្រជុំជន ក្នុងនោះរួមទាំងការគ្របដណ្តប់នៃសេវាគាំពារសុខភាពមាតានិងទារក សុខភាព កុមារ អត្រានៃការចាក់ថ្នាំបង្ការជំងឺផ្សេងៗនិងអត្រាធ្លាក់ចុះនៃជំងឺនានា ពិសេសគឺមេរោគអេដស៍ នេះបង្ហាញឲ្យឃើញពីភាពកាន់តែប្រសើរនៃសុខភាពប្រជារាស្ត្រ។ ការផ្តល់សេវាថែទាំសុខភាពមាតានិងទារកជាបញ្ហាចម្បងដែលក្រសួងសុខាភិបាល បានយកចិត្តទុកដាក់ ជាពិសេសគឺឥរិយាបទរបស់ឆ្មបទាំងអស់ ត្រូវប្រកាន់ភ្ជាប់នូវក្រមសីលធម៌របស់ខ្លួន ដើម្បីធ្វើឲ្យវិស័យសុខាភិបាលកាន់តែមានភាពរីកចម្រើននិងបង្កើននូវជំនឿទុកចិត្តពីសំណាក់ប្រជារាស្ត្រឲ្យកាន់តែខ្លាំងឡើងមកលើប្រព័ន្ធសុខាភិបាលបច្ចុប្បន្ន និងធ្វើឲ្យវិស័យនេះរឹតតែមានតួនាទីសកម្មថែមទៀតក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជារាស្ត្រ។ ដើម្បីទទួលបានលទ្ធផលនេះ ក្រុមការងាររបស់ក្រសួងសុខាភិបាលរួមទាំងគណៈឆ្មបកម្ពុជាបានរៀបចំចងក្រងសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មបដែលមានគោលដៅសំខាន់ៗដូចខាងក្រោម៖



-លើកកម្ពស់សីលធម៌របស់ឆ្មប

-លើកម្ពស់សេចក្តីព្រាងថ្លៃថ្នូរនិងភាពសុចរិតក្នុងការប្រកបវិជ្ជាជីវៈរបស់ឆ្មប

-លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាថែទាំក្នុងអំឡុងពេលមានគភ៌ ពេលសម្រាលកូន និងការអប់រំពិគ្រោះយោបល់ពីបញ្ហាសុខភាព(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យនេះ ហើយបានសម្រេចបង្កើតមាត្រ៤ថ្មីស្តីពីវាក្យសព្ទ ដោយបានស្នើដល់ក្រសួងសាមីឲ្យរៀបចំមាត្រា៤ថ្មីនេះ ដោយជ្រើសរើសយកតែវាក្យសព្ទសំខាន់ៗណាដែលបានប្រើក្នុងសេចក្តីព្រាងអនុក្រឹត្យនេះ មកដាក់តែប៉ុណ្ណោះ ហើយអង្គប្រជុំបានបន្តពិភាក្សាកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគលើមាត្រាផ្សេងៗទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានផ្អាកការពិភាក្សាលើសេចក្តីព្រាងនេះនៅមាត្រា៦ នឹងបន្តពិភាក្សានៅពេលក្រោយទៀត។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឆ្មប។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង

កាលពីថ្ងៃទី១៦ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទីនិងម៉ោង១៥:០០ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងបរិស្ថាន។



ក្រសួងបរិស្ថានបានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង សុខភាពសាធារណៈ គុណភាពបរិស្ថាន ជីវភាពរស់នៅរបស់ប្រជារាស្ត្រ និងរក្សាអត្តសញ្ញាណវប្បធម៌ ដោយផ្អែកលើបង្គោលគ្រឹះ៤គឺ សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្ពុជាជាប្រទេសហត្ថលេខីមួយក្នុងចំណោមប្រទេសហត្ថលេខីចំនួន១៦ នៃកិច្ចព្រមព្រៀងក្នុងការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល(GGGI) ដែលផ្តល់ផលប្រយោជន៍ ជួយជំរុញសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅកាន់សេដ្ឋកិច្ចបៃតង គឺផ្តោតលើប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តបៃតងដូចជា ពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទានបៃតង មីក្រូហិរញ្ញវត្ថុបៃតង និងវិនិយោគទុនបៃតង។

សម្រាប់ប្រទេសកម្ពុជា ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងនេះនឹងក្លាយជាយន្តការគ្រឹះឆ្លើយតបទៅនឹងគោលការណ៍សេដ្ឋកិច្ចបៃតងរបស់អង្គការសហប្រជាជាតិ ដោយផ្តោតលើកិច្ចការពារបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលអង្គការសហប្រជាជាតិបានប្រជុំសម្រេចយកគោលការណ៍នេះ នៅក្នុងសន្និសីទកំពូលភពផែនដី RIO+20 នៅប្រទេសប្រេស៊ីល។ ដូច្នេះ ប្រទេសកម្ពុជានឹងដើរឈានមុខគេ និងជាគំរូក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតងសហប្រជាជាតិ នៅក្នុងបណ្តាលប្រទេសអាស៊ាននិងអាស៊ីប៉ាស៊ីហ្វិក។ ដូច្នេះ ប្រទេសកម្ពុជានឹងដើរឈានមុខគេ និងជាគំរូក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍បៃតងសហប្រជាជាតិ នៅបណ្តាប្រទេសអាស៊ាននិងអាស៊ីប៉ាស៊ីហ្វិក(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យនេះ ហើយបានសម្រេចកែសម្រួលទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ ហើយបានបន្តពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង ដែលជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិនេះ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១២*



របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១២ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុនឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➡ នាខែកក្កដា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ស្ថិតនៅថេរធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។ ក្នុងនោះក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះធៀបនឹងខែមុនរួមមាន ម្ហូបអាហារ (-0,២%) ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ (-0,៨%) ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន (-0,១%) និងទំនិញនិងសេវាកម្មផ្សេងៗ (-0,៥%) ។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុនក្រុមទំនិញ និងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | |
|---|---|
| *ក្រុមទំនិញ:* | *មុខទំនិញ:* |
| ម្ហូបអាហារ : +១,២% | អង្ករ : +៥,៣% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : +១,៣% | សាច់ជ្រូក : -៦,៤% |
| សម្លៀកបំពាក់ និងស្បែកជើង : +៤,៨% | សាច់គោស្រស់: +១៣% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : +៣,0% | សាច់មាន់ : -១,៧% |
| ការដឹកជញ្ជូន: -0,៤% | ត្រីស្រស់ : -៦,៦% |
| ភោជនីយដ្ឋាន: +៣,0% | បន្លែ: +១១% |
| ទំនិញនិងសេវាកម្មផ្សេងៗ: +៣,៥% | ឧស្ម័ន: -៣,៦% |
| | ប្រេងសាំង: -៤,៧% |
| | ប្រេងម៉ាស៊ូត: -៤,១%។ |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខនៃតារាងទាំង៥ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្ដីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ ។

**តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០-២០១២**

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា[P] | កញ្ញា[P] | តុលា[P] | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ១,៧% | ១,២% | ០,៩% | | | ២,៦% |
| | ខែមុន | ១,០ | ០,៤ | ០,៦% | ០,៥% | -១,១% | ០,១% | ០ | ០,៥% | ០,៥% | -០,២% | | | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៧% | -០,៨% | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | -១,០% | -០,២% | |

P: តួលេខខែ សីហា កញ្ញា និងតុលា ឆ្នាំ២០១២ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

**ក្រាហ្វ ១. បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១១ និង២០១២ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)**




ក្រាហ្វបង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ(ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១២ និង ២០១១។ ក្រាហ្វក៏បង្ហាញផងដែរ នូវអត្រាអតិផរណាព្យាករបីខែទៅមុខ (ធៀបនឹងខែដូចគ្នាឆ្នាំមុន) ក្នុងឆ្នាំ២០១២។

➡**អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | អត្រាខែកក្កដា ២០១២ | អត្រាខែមិថុនា ២០១២ | អត្រាខែកក្កដា ២០១១ | *ប្រភេទ* | អត្រាខែកក្កដា ២០១២ | អត្រាខែមិថុនា ២០១២ | អត្រាខែកក្កដា ២០១១ |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៤០៧០រ/១$ | ៤០៧៥រ/១$ | ៤១០០រ/១$ | បាត/ដុល្លារ | ៣១,៥៨បាត/១$ | ៣១,៨៨បាត/១$ | ២៩,៧០បាត/១$ |
| រ/បាត | ១២៩រ/១បាត | ១២៧រ/១បាត | ១៣៨រ/១បាត | ដុង/ដុល្លារ | ២០៨៤០ដុង/១$ | ២០៩០០ដុង/១$ | ២០៥២០ដុង/១$ |
| រ/ដុង | ០,១៩៥រ/១ដុង | ០,១៩៤រ/១ដុង | ០,១៩៨រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែកក្កដា **ឆ្នាំ២០១២ ថវិកាជាតិមាន**ស្ថានភាពដូចខាងក្រោមៈ

- *ចំណូលថវិកាជាតិអនុវត្តបានចំនួន ៦១៦,១ ពាន់លានរៀល (មធ្យមប្រចាំខែ ៧២% នៃគម្រោង) ក្នុងនោះ* ចំណូលចរន្តចំនួន ៦១៦,១ពាន់លានរៀល (មធ្យមប្រចាំខែ ១០០% នៃគម្រោង) និងពុំមានចំណូលមូលធនទេ ។

- បើធៀបនឹងខែមុន**ចំណូលថវិកាជាតិ**ថយចុះ ១៧% ប៉ុន្តែកើនឡើង ២១% *ធៀបនឹងខែដូចគ្នាឆ្នាំមុន*។ កំណើនធៀបនឹងខែដូចគ្នាឆ្នាំមុន ជារួមបណ្តាលមកពីចំណូលចរន្តកើនឡើង ២១%។

- នៅក្នុងចំណូលចរន្ត៖

**ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១១ និង ២០១២ (ពាន់លានរៀល)**



✓ ចំណូលសារពើពន្ធមានចំនួន ៥៦៣,៤៣ពាន់លានរៀល កើនឡើង១០% ធៀបនឹងខែមុន និងកើនឡើង២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។

✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៥២,៧៣ពាន់លានរៀល ថយចុះ១០% ធៀបនឹងខែមុន និងថយចុះ២២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| ក្នុងចំណូលសារពើពន្ធ<br>(ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | ក្នុងចំណូលមិនមែនសារពើពន្ធ<br>(ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : -២% | (+១២%) | ➢ នេសាទ: +១០៦៩% | (-៣៦%) |
| ➢ ចំណូលពន្ធដារ : +១៨% | (+៧៣%) | ➢ រុក្ខាប្រមាញ់ : +១៦៤០% | (+១៦៥%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗ: +៥៧% | (+៧២%) | ➢ អាកាសចរណ៍ស៊ីវិល : -៤៣% | (+៨៦%) |
| ✧ កាស៊ីណូ : -៥% | (+១៥៩%) | ➢ ផលទុនទេសចរណ៍: -៩៥% | (-៩៣%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : +៦១០% | (+៤៥៦%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +៤១% | (-៩%) |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ : +៦៩% | (+១៧%) | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): -២៤% | (-២៥%) |

↳ ***ចំណាយថវិកាជាតិ*** អនុវត្តបានចំនួន ៩៨៥ពាន់លានរៀល ( *មធ្យមប្រចាំខែ ៦១% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៨៩២ ពាន់លានរៀល( *មធ្យមប្រចាំខែ ៩២% នៃគម្រោង*) និង**ចំណាយមូលធន**ចំនួន ៩៣ ពាន់លានរៀល។

↳ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** កើនឡើង ៦១% និងកើនឡើង ៩៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃ**ចំណាយថវិកាជាតិ** ជាចំបងបណ្តាលមកពីការកើនឡើងនៃចំណាយចរន្ត។

↳ *ថវិកាជាតិនៃខែកក្កដាមាន **ឱនភាព ៣៦៩** ពាន់លានរៀល ស្មើនឹង ៩១ លានដុល្លារ ស.រ.អា ។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកក្កដា ឆ្នាំ២០១២ មានលក្ខណៈដូចខាងក្រោម៖

↳ រូបិយវត្ថុ $M_2$ មានចំនួន ២៦៧៩៤ ពាន់លានរៀល កើនឡើង ០,៥% ធៀបនឹងខែមុន និងកើនឡើង ២០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

↳ កំណើនរូបិយវត្ថុ $M_2$ ធៀបនឹងខែមុន ជារួមបណ្តាលមកពី រូបិយវត្ថុក្រៅធនាគារកើនឡើង ០,៦% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ១,២%។

↳ យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៧% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣%។

**ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែកក្កដា ឆ្នាំ២០១២**



| សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៩,២% | ១៨,៣% | ១៩,៦% | ១៩,៣% | ១៨,៦% | ១៨% | ១៧% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,២% | ១៥,២% | ១៥,៣% | ១៤,៨% | ១៤,៧% | ១៤% | ១៤% | | | | | |

## បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែ កក្កដា២០១២៖ ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣១៦៧ **លានដុល្លារ** កើនឡើង ១,៣% ធៀបនឹងខែមុន និងកើនឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន **៩២០៧ ពាន់លានរៀល** កើនឡើង ២% ធៀបនឹងខែមុន និងកើនឡើង ១៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** *ជារួមមានការកើនឡើង* ។ ក្នុងខែនេះមានចំនួន **២០៦១១ ពាន់លានរៀល** កើនឡើង ១,១% ធៀបនឹងខែមុន និងកើនឡើង ៣៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** (ខែកក្កដាមិនទាន់មានតួលេខ)
- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែកក្កដា៖

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាមុន* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៧៩% | –០,៣% | –១១% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១២,១២% | ០ | **–៤៦%** |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤៣% | +០,៥% | **+២%** |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១២,១១% | **–៤%** | **–២៨%** |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែកក្កដា ឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

**កសិកម្ម៖**

✓ ផលិតកម្មនេសាទមានចំនួន២១ពាន់តោន ថយចុះ៤២% ធៀបនឹងខែមុន និងថយចុះ៤៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**ឧស្សាហកម្ម៖**

✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៧៨ GWh កើនឡើង២% ធៀបនឹងខែមុន និងកើនឡើង ២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ អគ្គិសនីផ្គត់ផ្គង់ដោយរ៉ាវីអគ្គិសនីមានចំនួន ៦០,៤ GWh កើនឡើង១៤% ធៀបនឹងខែមុន និងកើនឡើង១៩២៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤០៦ លានដុល្លារ កើនឡើង១១% ធៀបនឹងខែមុន និងកើនឡើង ៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម៖

| *ប្រភេទ* | *ចំនួន –កក្កដា២០១២* | *ចំនួន– មិថុនា២០១២* | *ចំនួន–កក្កដា២០១១* |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៧ | ៨ | ៨ |

↳ **សំណង់** (ការអនុញ្ញាត)៖

✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១៦៣៩ ពាន់ម² កើនឡើង ២១៣% ធៀបនឹងខែមុន និងកើនឡើង ៣២៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់**ស្មើនឹងចំនួន ៥១៨ លានដុល្លារ** កើនឡើង ២៥៤%ធៀបនឹងខែមុន និងកើនឡើង ៣៧១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន៖**

| *ប្រភេទ* | *ពាន់ម² –កក្កដា ២០១២* | *ពាន់ម² –មិថុនា២០១២* | *ពាន់ម² –កក្កដា ២០១១* |
|---|---|---|---|
| ▪ លំនៅឋាន | ១១៧៩ | ១០៥ | ២៧១ |
| ▪ ឧស្សាហកម្ម | ៣៩៨ | ៣៣០ | ៧៧ |
| ▪ ទេសចរណ៍ | ១២ | ៦៧ | ១៦ |
| ... | | | |
| អនុញ្ញាតសរុប | ១៦៣៩ | ៥២៤ | ៣៨៦ |

✓ **សំណង់ដែលពេញនិយម**នាខែនេះគឺ សំណង់លំនៅឋាន (៧២% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងឧស្សាហកម្ម (២៤% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

↳ **ការងារ៖**

| *ប្រភេទ* | *ចំនួន (នាក់)–កក្កដា២០១២* | *%Δ ធៀបនឹងខែមុន* | *%Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ២៦១៩ | +២៨% | +២០% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣៧៨៨ | -៤% | +៤៩% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៥៥៩ | -៣៣% | +១០០% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៣៩៦ | +៤៧% | +៣៦% |

↳ **វិនិយោគ៖**

✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែកក្កដាមានចំនួន ២១ គម្រោង ដែលជាទុនវិនិយោគស្មើនឹង ១៨០ **លានដុល្លារ**។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន ៣១ **ពាន់នាក់**។

| *ប្រភេទ* | *កក្កដា២០១២* | *មិថុនា២០១២* | *កក្កដា២០១១* |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ១៨០ | ៤៦៣ | ២៦៥៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៤៧ | ៥២ | ១៥៧ |
| វិស័យឧស្សាហកម្ម | ១៣៣ | ៤១១ | ២២៩០ |
| វិស័យទេសចរណ៍ | ០ | ០ | ២០៦ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ២ |
| **ចំនួនគម្រោង ថ្មីនិងពង្រីក** (ចំនួន) | ២១ | ៣១ | ២៤ |
| **បង្កើតការងារ** (ពាន់នាក់) | ៣១ | ៣៨ | ១៩ |

**សេវាកម្ម និងទេសចរណ៍៖**

✓**ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន—កក្កដា២០១២ | ចំនួន—មិថុនា២០១២ | ចំនួន—កក្កដា២០១១ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៩៥ | ២៧៩ | ២៩៣ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២ | ២ | ៥ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ២២៥ | ១៦៣ | ៣០៨ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៤៦៣ ពាន់តោន កើនឡើង ១% ធៀបនឹងខែមុន និងកើនឡើង ៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: +១៨% | (+១១%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +២០% | (−៤០%) |
| ▪ កំពង់ផែកំពង់សោម: −៩% | (+២%) | ▪ កំពង់ផែឧកញ៉ាម៉ុង: −៧% | (+២២១%) |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៥ | +១៦% | +១៩% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១២ | +២១% | +១៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៩៣ | +១៩% | +៣៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៦ | -១% | +២% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៨៤ | +១៣% | +១៩% |
| ✓ តាមផ្លូវអាកាស | ១២៦ | +១៩% | +១០% |
| ✓ តាមផ្លូវគោក និងទឹក | ១៥៨ | +៩% | +២៨% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែកក្កដាមានចំនួន ២៦១៦ ពាន់លានរៀល (ស្មើនឹង ៦៤៣ លានដុល្លារ ស.រ.អា.) ថយចុះ ២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២០% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +៧% | +១៩% | រថយន្តសរុប (គ្រឿង) | −២៣% | +១១% |
| ប្រេងម៉ាស៊ូត | +១៦% | +៣% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | −២៥% | −២២% |
| ប្រេងខ្មៅ | −១៧% | −២៤% | គ្រឿងអេឡិចត្រូនិក | −២៩% | −២៧% |
| ឧស្ម័ន | +៦% | +៦៧% | ម៉ូតូ (គ្រឿង) | −១៧% | +២៣% |
| ស៊ីម៉ង់ត៍ | +៩៩% | +១០៩% | ផ្លែឈើ និងបន្លែ | −១៦% | −៤៥% |
| ដែកសំណង់ | −១៣% | +៣៤% | ជីនិងថ្នាំកសិកម្ម | −១៥% | −៦% |
| រថយន្តសរុប (ព.ល.រ) | −២៨% | +១១% | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៥៧៥% | +១៣៤៨% |

➡ **ការនាំចេញ** ក្នុងខែកក្កដាឆ្នាំ២០១២ មានចំនួន ២០៩១ ពាន់លានរៀល ស្មើនឹង ៥១៤ លានដុល្លារ ស.រ.អា. (៨០% នៃការនាំចូល) ថយចុះ ៣% ធៀបនឹងខែមុន និងថយចុះ ៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | −៩៥% | −២% | កៅស៊ូ | +៥៥% | −១% |
| វាយនភណ្ឌនិងស្បែកជើង | −៣% | −១១% | ផលិតផលនេសាទ | +១៤% | −៦០% |
| អង្ករ | +០,១% | +១២% | | | |

➡ ក្នុងខែកក្កដានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៥២៦៣ាន់លានរៀល ស្មើនឹង ១២៩ លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកក្កដា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | អាករនាំចេញ | -២៩% | -៤៤% | — |
| ២ | ផលទុននៃសកម្មភាពទេសចរណ៍ | -៩៥% | -៩៣% | — |
| ៣ | សំណង់ទេសចរណ៍ | -៨២% | -២៨% | — |
| ៤ | ទុនវិនិយោគអនុញ្ញាតដោយ ក.អ.ក. | -៦១% | -៩៣% | — |
| ៥ | ការនាំចូលស៊ីម៉ង់ត៍ | +៩៩% | +១០៩% | — |
| ៦ | ការនាំចូលអង្ករ (៧៨,២ ពាន់តោន) | កើនយ៉ាងគំហុក | កើនយ៉ាងគំហុក | នាំចូលពីវៀតណាម ដើម្បីនាំចេញទៅថៃ។ ជាប្រភេទចុងអង្ករ (បំភ្លឺដោយតំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករ) |
| ៧ | ការនាំចេញផលិតផលវាយនភណ្ឌនិងស្បែកជើង | -៣% | -១១% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) មូលហេតុមួយដែលថ្លៃប្រេងសាំងនៅកម្ពុជាមានកម្រិតខ្ពស់ គឺដោយសារភាពមិនសុក្រឹតនៃទីផ្សារ ក្នុងនោះការប្រកួតប្រជែងនៅមានកម្រិត និងការយកកម្រៃចំណេញខ្ពស់ពេក។ ការណ៍នេះបង្ហាញតាមរយៈការលក់តាមថ្លៃខុសគ្នាខ្លាំង រវាងស្ថានីយនិងស្ថានីយក្នុងតំបន់ប្រជុំជន តំបន់ជាយក្រុង និងជនបទ។

២) យោងតាមពត៌មានពីតំណាង ក.អ.ក. មានការត្អូញត្អែររបស់វិនិយោគិនបរទេសមួយចំនួនអំពីកម្ពុជាកំពុងខ្វះកម្លាំងពលកម្មបម្រើឲ្យឧស្សាហកម្មក្នុងស្រុក ខណៈពេលដែលមានលំហូរចេញនៃពលករជាច្រើនទៅបម្រើឲ្យឧស្សាហកម្មក្រៅប្រទេស។

៣) ការថយចុះនៃថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិ នាំឲ្យតម្លៃនាំចេញកៅស៊ូមានការថយចុះ។

***សេចក្តីសន្និដ្ឋាន៖***

១) បើសិនជាមានការកំណត់កម្រៃចំណេញ (Profit Margin) ក្នុងកម្រិតសមរម្យណាមួយចំពោះប្រេងឥន្ធនៈនោះថ្លៃប្រេងឥន្ធនៈអាចនឹងចុះថោកខ្លះ និងមានឥទ្ធិពលល្អចំពោះថ្លៃទំនិញ និងសេវាកម្មផ្សេងទៀត។

២) មូលហេតុដែលពលករកម្ពុជាចេញទៅបម្រើឲ្យឧស្សាហកម្មក្រៅប្រទេស និងមិនចូលបម្រើសង្វាក់ផលិតកម្មក្នុងស្រុក មានដូចជា :
- ប្រាក់កម្រៃពលកម្មក្នុងស្រុកទាបជាងប្រាក់កម្រៃពលកម្មក្រៅស្រុក
- ពលករមិនបានដឹងអំពីតម្រូវការកម្លាំងពលកម្មនៅក្នុងស្រុក
- ការខ្វះជំនាញដើម្បីចូលក្នុងសង្វាក់ផលិតកម្ម។

៣) ដើម្បីបង្កើនការនាំចេញ និងលើកកម្ពស់ជញ្ជីងពាណិជ្ជកម្ម កម្ពុជាត្រូវតែពង្រឹងមូលដ្ឋានឧស្សាហកម្មធុនស្រាល និងកសិឧស្សាហកម្មឲ្យបាន។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៨/១២<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ២ | ០១/០៨/១២<br>ម៉ោង ១៦ : ០០ នាទី | ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim Chon Song អ្នកគ្រប់គ្រងក្រុមហ៊ុន ម៉ាន់ស៊ូដេញតិច និងសហការី នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០២/០៨/១២<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/០៨/១២<br>រយៈពេល ០១ ថ្ងៃ | ចូលរួមក្នុងអង្គប្រជុំស្តាប់ការផ្សព្វផ្សាយ "របាយការណ៍បូកសរុបការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី ៣ និងទិសដៅឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ ឆ្នាំ ២០១៣" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នៅស្នាក់ការកណ្តាលគណបក្ស(គ៨៥)។ |
| ៥ | ០៩/០៨/១២<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមអមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាក្នុងកិច្ចប្រជុំរដ្ឋសភា នៅរដ្ឋសភាជាតិ។ |
| ៦ | ០៩/០៨/១២<br>ម៉ោង ១៦ : ០០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់អាយុចូលនិវត្តន៍ ដល់មន្ត្រីរាជការស៊ីវិល (ឬជាស្ត្រី)។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១០/០៨/១២<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់អាយុចូលនិវត្តន៍ ដល់មន្ត្រីរាជការស៊ីវិល (ឬជាស្ត្រី)។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
| --- | --- | --- |
| ៨ | ១០/០៨/១២<br>ម៉ោង ១៦ : ០០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារជំនាញផ្នែកស្ថាបត្យកម្ម ក្រុមការងារផ្នែកវប្បធម៌ និងទីប្រឹក្សាបច្ចេកទេស សម្រាប់គម្រោងសាងសង់អគារសារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៥/០៨/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទវគ្គប្រគល់សញ្ញាបត្រកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងកម្រិតបណ្ឌិត ជូនដល់និស្សិត នៃសាកលវិទ្យាល័យ បៀលប្រាយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១០ | ១៥/០៨/១២<br>ម៉ោង ១៥ : ៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានា នៃរមណីយដ្ឋានអង្គរ ក្នុងខេត្តសៀមរាប។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាន សម្រាប់មន្ត្រីក្របខណ្ឌ មន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ២០/០៨/១២<br>ម៉ោង ០៨ : ៣០នាទី | ជាអធិបតីភាព ក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគម្រោងវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារភ្នំពេញ។ |
| ១២ | ២៤/០៨/១២<br>ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់គ្រប់គ្រង និងការពារសត្វផ្សោតទន្លេមេគង្គ។<br>៣-បញ្ហាផ្សេងៗ<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | **២៧/០៨/១២**<br>**ម៉ោង ០៨ : ៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសម័យប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៤៤ និងកិច្ចប្រជុំពាក់ព័ន្ធ (44th Asean Economic Ministers (AEM) Meeting and Related Meetings) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Apsara Angkor Resort and Conference ក្រុងសៀមរាប។ |
| ១៤ | **២៨/០៨/១២**<br>**ម៉ោង ១៧ : ០០នាទី** | ជួបប្រជុំពិភាក្សាការងារ អំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយ ឯកឧត្តម **តិច សំណាង** និងឯកឧត្តម **ម៉ិច សុខា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៩/០៨/១២**<br>**ម៉ោង ០៧ : ៤៥នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីជូនដំណើរគណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអញ្ជើញចូលរួមកិច្ចប្រជុំកំពូលលើកទី១៦ នៃចលនាមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងតេអេរ៉ង់ នៃសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ និងបន្តទៅចូលរួមពិធីបើកពិព័រណ៍ចិន-អាស៊ីអឺរ៉ុបលើកទី២ នៅទីក្រុងអ៊ូរូមហ្គី នៃសាធារណរដ្ឋប្រជាមានិតចិន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៦ | **២៩/០៨/១២**<br>**ម៉ោង ០៨ : ៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា ឆ្នាំ២០១២ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **៣០/០៨/១២**<br>**ម៉ោង ១៥ : ០០នាទី** | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៨ | **៣១/០៨/១២**<br>**ម៉ោង ០៩ : ០០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ឯក សុនចាន់** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **៣១/០៨/១២**<br>**ម៉ោង ១៥ : ០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៣/០៨/១២ | ដឹកនាំសិក្ខាសាលាស្តីពីការបូកសរុបការងារគម្រោងវាយតម្លៃលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| ២ | ១៥/០៨/១២ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានា នៃរមណីយដ្ឋានអង្គរ ក្នុងខេត្តសៀមរាប។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាន សម្រាប់មន្ត្រីក្របខណ្ឌ មន្ត្រីជាន់ ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២០/០៨/១២ | ចូលរួមក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគម្រោងវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារភ្នំពេញ។ |
| ៤ | ២៧/០៨/១២ | ដឹកនាំប្រជុំគណៈកម្មការ ជាមួយក្រុមហ៊ុនចម្រុះ " សិប្បករអង្គរ " នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## ឯកឧត្តម ឌុយ ផៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៩/០៨/១២ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់អាយុចូលនិវត្តន៍ ដល់មន្ត្រីរាជការស៊ីវិល (ឬជាស្ត្រី)។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១០/០៨/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់អាយុចូលនិវត្តន៍ ដល់មន្ត្រីរាជការស៊ីវិល (ឬជាស្ត្រី)។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ២០/០៨/១២ | ចូលរួមក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគម្រោងវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារភ្នំពេញ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១២

## ឯកឧត្តម ង៉ាន់ ភិរុណ អគ្គលេខាធិការ

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៩/០៨/១២ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់អាយុចូលនិវត្តន៍ ដល់មន្ត្រីរាជការស៊ីវិល (ឬជាស្ត្រី)។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១០/០៨/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងរបាយការណ៍ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកំណត់អាយុចូលនិវត្តន៍ ដល់មន្ត្រីរាជការស៊ីវិល (ឬជាស្ត្រី)។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១៥/០៨/១២ | ចូលរួមក្នុងអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងកិច្ចការពាររូបភាពប្រាសាទនានា នៃរមណីយដ្ឋានអង្គរក្នុងខេត្តសៀមរាប។<br>២-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ។<br>៣-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីសញ្ញាសក្តិ និងឯកសណ្ឋាន សម្រាប់មន្ត្រីក្របខណ្ឌ មន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ។<br>៤-សេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។<br>៥-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ២០/០៨/១២ | ចូលរួមក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ស្តីពីគម្រោងវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត នៅសណ្ឋាគារភ្នំពេញ។ |

# សិក្ខាសាលាស្តីពីការពិគ្រោះយោបល់នៃគម្រោងវិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ( RIA ) ជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ នៅសណ្ឋាគារភ្នំពេញ បានរៀបចំសិក្ខាសាលាមួយស្តីពីការពិគ្រោះយោបល់នៃគម្រោងវិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA ) ជាមួយក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រោមអធិបតីភាព ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ អនុប្រធាន សមាជិក សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងថ្នាក់ដឹកនាំ-មន្ត្រីអគ្គលេខាធិការដ្ឋាន មន្ត្រីគម្រោងRIA ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មន្ត្រីគម្រោងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា។



ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ឃឹម ណុលឡា** បានជម្រាបអំពីពត៌មាននៃគម្រោងវិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត( RIA ) ដែលមានសារតាចាប់តាំងពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ ADB បានផ្តល់ហិរញ្ញប្បទានដល់កម្មវិធីពិពិធកម្មសេដ្ឋកិច្ច "Promoting Economic Diversification" ( PED ) ដែលគ្រប់គ្រងដោយក្រសួងពាណិជ្ជកម្ម ដើម្បីគាំទ្រដល់អាទិភាពកែទម្រង់របស់រដ្ឋាភិបាល តម្រង់ឲ្យមានប្រភព-



ច្រើនប្លែកគ្នាសម្រាប់កំណើនសេដ្ឋកិច្ច រួមទាំងការខំប្រឹង ធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចក្នុងវិស័យពាណិជ្ជកម្ម ដោយផ្សព្វផ្សាយនយោបាយប្រទ្បងប្រណាំង និងប្រសិទ្ធភាពនៃលិខិតបទដ្ឋានគតិយុត្ត។ PED មានអនុកម្មវិធីទាំងអស់ ៣ ក្នុងនោះ អនុកម្មវិធីទីចំនួន៣ បានត្រូវ ADB កំពុងរៀបចំផ្តល់ឥណទានបន្តទៀត។

ចាប់ពីឆ្នាំ២០០៨ នៅក្នុង PED អនុកម្មវិធីទី១ ADB បានបញ្ចូលវិធីអនុវត្ត RIA សម្រាប់រៀបចំប្រកាសនៅក្រសួងឧស្សាហកម្ម ជាគម្រោងពិសោធន៍រយៈពេល០២ឆ្នាំ ហើយឃើញថាមានប្រសិទ្ធភាពទើបដល់ឆ្នាំ២០១០ ADB បានចាប់គិតគូរពង្រីកវិធីអនុវត្ត RIA សម្រាប់រៀបចំបញ្ញត្តិកម្មថ្មី ទៅក្រសួងដទៃទៀត ហើយយកគម្រោង RIA ឲ្យមកនៅក្នុង ECO-SOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី ។



ដោយមានការគាំទ្រពី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** អនុស្សារណៈយោគយល់គ្នាចំនួន ០២ បានត្រូវចុះហត្ថលេខាជាមួយ ADB ដើម្បីប្រតិបត្តិនិងអនុវត្តគម្រោងRIA ដែលស្ថិតនៅក្រោម ECOSOCC ។ ឯកឧត្តម **ឃឹម ណុលឡា** ក៏បានជម្រាបផងដែរថា នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២នេះ យើងគ្រោងរៀបចំពិធីសម្ពោធផ្សព្វផ្សាយគម្រោង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីលើកទឹកចិត្តឲ្យក្រសួងដទៃយល់ដឹង នឹងចូលរួមអនុវត្តគម្រោងនេះ។

ជាចុងក្រោយ ដើម្បីឲ្យគម្រោងទាំងមូលសម្រេចបានជោគជ័យ យើងត្រូវតែសហការទាំងអស់គ្នា ហើយរៀនសូត្រចែករំលែកបទពិសោធន៍ និងចេះជួយគ្នាទៅវិញទៅមក។ មន្ត្រីគម្រោងត្រូវមានឆន្ទៈការងារ ព្រមទាំងចំណាយពេលវេលាធ្វើការងារគម្រោងដោយយកចិត្តទុកដាក់ និងឲ្យបានពេញលេញ ហើយបើយើងមានការជាប់រវល់ខ្លាំងពេក គួរជំរុញឲ្យមានមន្ត្រីផ្សេងមកជំនួស។

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ម៉ាន់ គិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ធារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត កក្កដា | មន្ត្រី ក.ស.វ. |




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in